**ព្រឹទ្ធសភា**

**អគ្គលេខាធិការដ្ឋាន**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ២០២៣

នៅក្នុងខែមីនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្ដល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

-បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក និងបើកសម័យប្រជុំព្រឹទ្ធសភាលើកទី១០ នីតិកាលទី៤ ចំនួន០១លើក ដើម្បី៖

១-ស្ដាប់របាយការណ៍ស្ដីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៩ និងលើកទី១០ នីតិកាលទី៤

២-ពិនិត្យ និងអនុម័តលើសេចក្ដីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

-បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភាហត្ថលេខី អញ្ជើញចូលរួមឆ្លើយបំភ្លឺលើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅក្រុមប្រឹក្សាធម្មនុញ្ញ។

**២- មុខងារតាមដានការអនុវត្តច្បាប់**

-បានរៀបចំទីកន្លែង និងផ្ដល់សេវាក្នុងពិធីជំនួបពិភាក្សាការងារជូនគណៈកម្មការទី៥ព្រឹទ្ធសភា ជាមួយ៖

- ឯកឧត្តមនាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ ដើម្បីឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍ និងដំណើរការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពី អន្តោប្រវេសន៍ថ្មី នៅវិមានព្រឹទ្ធសភា



វិមានវិថីចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oumsarith_sgsenate@gmail.com, oumsarith_sgsenate@yahoo com

❖ ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដើម្បីស្តាប់របាយការណ៍ស្តីពី លទ្ធផលការងារសម្រេចបានរបស់ក្រសួងព័ត៌មានក្នុងឆ្នាំ២០២២ និងទិសដៅអនុវត្តសកម្មភាពបន្តឆ្នាំ២០២៣ យន្តការ និងវិធានការនៃការគ្រប់គ្រងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ អ្នកសារព័ត៌មាន តាមបណ្តាញសង្គម ដែលកំពុងមានសកម្មភាពនាពេលបច្ចុប្បន្ន និងការវិវត្តនៃដំណើរការកសាងសេចក្តីព្រាងច្បាប់ស្តីពី សិទ្ធិទទួលព័ត៌មាន នៅវិមានព្រឹទ្ធសភា

**-បានរៀបចំចាត់ចែង និងផ្តល់សេវាជូនៈ**

❖ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញចុះបេសកកម្មដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការនៅថ្នាក់មូលដ្ឋាន ការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព និងការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ ព្រមទាំងស្តាប់នូវបញ្ហាប្រឈម សំណូមពរ ដែលអាជ្ញាធរឃុំបានជួបប្រទះចំពោះការអនុវត្តការងារនាពេលកន្លងមក នៅខេត្តត្បូងឃ្មុំ

❖ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ អញ្ជើញចុះបេសកកម្មដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ ការធ្វើលិខិតបទដ្ឋានគតិយុត្ត ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព នៅខេត្តបាត់ដំបង។

**៣-មុខងារតំណាង**

**-បានរៀបចំចាត់ចែង និងផ្តល់សេវាជូនៈ**

❖ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា

- អញ្ជើញទទួលព្រះរាជដំណើរ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ស្តេចយាងនិវត្តន៍ពីទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជា-មានិតចិន មកកាន់មាតុប្រទេសវិញ
- អញ្ជើញជាអធិបតីក្នុងពិធីកាត់ឫសសីមាព្រះវិហារថ្មី និងសម្ពោធដាក់ឱ្យប្រើប្រាស់សមិទ្ធផលនានា ក្នុងវត្តមុនីជីខលើ នៅស្រុកស្រែអំបិល ខេត្តកោះកុង
- ទទួលជួបសំណេះសំណាលជាមួយគណៈប្រតិភូស្ត្រីមកពីក្រសួងកិច្ចការនារីចំនួន២០០នាក់ ដឹកនាំដោយលោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ក្នុងឱកាសនៃការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣

- អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី និងអាជ្ញាធរសង្កាត់ទឹកល្អក់ទី៣ នៅខណ្ឌទួលគោក រាជធានីភ្នំពេញ
- បានចាត់ឱ្យលោកជំទាវ **សាយ ចាន់ណាក់** នាំយកថវិការបស់សម្ដេចប្រធានព្រឹទ្ធសភា ចូលរួមបុណ្យសពឧបាសិកា **ហ៊ីង សាវ៉េត** និងបានចុះសួរសុខទុក្ខឯកឧត្តម **អាយ ខន** សមាជិកព្រឹទ្ធសភា និងឯកឧត្តម **ញាណ គៀន** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ដែលកំពុងសម្រាក និងព្យាបាលជំងឺ

❖ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា

- អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកអង្គវេទិការបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
- អញ្ជើញចុះពិនិត្យវឌ្ឍនភាពនៃការកសាងអគារសិក្សាថ្មី១ខ្នង នៅសាលាបឋមសិក្សាទេពនិម្មិត និងនាំយកទេយ្យវត្ថុ គ្រឿងឧបភោគបរិភោគ រួមទាំងបច្ច័យមួយចំនួនប្រគេនព្រះសង្ឃគង់ក្នុងវត្តទេពនិម្មិត និងវត្តពង្រវង្ស៊ី នៅខេត្តព្រៃវែង
- អញ្ជើញចូលរួមពិធីស្រោចស្រពសុគន្ធវារីឡើងគេហដ្ឋាននៅភូមិគ្រឹះ**សម្ដេចអគ្គមហា-ពញាចក្រី ហេង សំរិន** នៅខេត្តត្បូងឃ្មុំ

❖ **ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា

- អញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរស្រុក ក្រុងទាំង១១ ក្នុងខេត្តកណ្ដាល
- អញ្ជើញចុះពិនិត្យការកសាងព្រះវិហារថ្មី នៅវត្តលុម្ពិនីសាលវ័នអារាម (ហៅវត្តអូរសោម) នៅស្រុកវាលវែង ខេត្តពោធិ៍សាត់

❖ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានរៀបចំវេទិកាជាមួយក្រុមប្រឹក្សាសង្កាត់ស្ដីពីការអភិវឌ្ឍមូលដ្ឋាន និងបម្រើប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ធានាបានសុខសន្តិភាព ចំនួន១៤ខណ្ឌ ទូទាំងរាជធានីភ្នំពេញ

❖ ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (ក.ជ.ក.ស) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្ដីការគណៈរដ្ឋមន្ត្រី

- ក្រុមសមាជិកព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ដែលជាអំណោយរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា ចែកជូនមណ្ឌលសុខភាព អាជ្ញាធរខេត្ត អាជ្ញាធរស្រុក និងអាជ្ញាធរឃុំ-សង្កាត់ នៅរាជធានីភ្នំពេញ ខេត្តកំពត ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ ខេត្តបាត់ដំបង និងខេត្តស្ទឹងត្រែង
- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ឆេង** ប្រធានគណៈកម្មការទី២ ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំរៀបចំគ្រឿងឥស្សរិយយសជូនសមាជិកព្រឹទ្ធសភា សម្រាប់បំពាក់ជូនសមាជិកព្រឹទ្ធសភា នៅចុងនីតិកាលទី៤
- សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យទន្លេលើកទី៧ ឆ្នាំ២០២៣ ក្រោមប្រធានបទ "ទន្លេរបស់យើង ដើម្បីបច្ចុប្បន្ន និងអនាគត" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តកំពង់ធំ
- ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី២ អនុញ្ញាតឱ្យឯកឧត្តម **អៀង អូនី** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ចូលជួបសម្ភាសន៍អំពីប្រវត្តិនៃការបង្កើតក្រសួងមហាផ្ទៃ នៅវិមានព្រឹទ្ធសភា
- លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល និងចែកអំណោយជូនប្រជាពលរដ្ឋ នៅសាលាឃុំក្សេមក្សាន្ត ខេត្តកំពង់ស្ពឺ
- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ ព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល និងអញ្ជើញសម្ពោធបណ្ណាល័យ១ខ្នង ក្នុងសាលាបឋមសិក្សាបឹងក្អែក នៅស្រុកពាមរក៍ ខេត្តព្រៃវែង
- លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ ព្រឹទ្ធសភា អញ្ជើញជាអធិបតីៈ
  - ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាថ្នាក់មូលដ្ឋានស្តីពី គម្រោងភាពជាដៃគូ សម្រាប់គំនិតច្នៃប្រឌិតរបស់ទីក្រុងលើការដឹកនាំរបស់ស្ត្រីនៅមូលដ្ឋាន (PMI-WILL) នៅវិមានព្រឹទ្ធសភា
  - សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារប្រចាំឆ្នាំ២០២៣ របស់សាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និងពិធីអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ ដែលរៀបចំឡើងដោយរដ្ឋបាលខេត្តកំពត នៅសាលសន្និសីទបូកគោ ខេត្តកំពត
  - ក្នុងពិធីសំណេះសំណាល និងចែកចង្រ្កានសន្សំសំចៃថាមពលជូនប្រជាពលរដ្ឋក្រុងកែប

ចំនួន១,៤០៥គ្រួសារ នៅពហុកីឡដ្ឋានខេត្តកែប

❖ សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ និងក្រុមការងាររបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ធន** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋក្រីក្រ នៅខេត្តកណ្តាល ខេត្តតាកែវ និងខេត្តកែប

❖ ដោយឡែកសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន-យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ពិសេសបាននាំយកថ្នាំពេទ្យ បរិក្ខារពេទ្យ ឧបករណ៍តេស្តរហ័សជូនអាជ្ញាធរ និងមណ្ឌលសុខភាព នៅតាមបណ្តាខេត្ត ក្រុងនានាចំនួន១១៨លើក ព្រមទាំងបានចូលរួមពិធីផ្សេងៗចំនួន១០០លើក

-ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការ និងឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរសង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកតាសេក សង្កាត់ព្រែកលៀប សង្កាត់បាក់ខែង និងសង្កាត់កោះដាច់ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រមទាំងបាននាំយកអំណោយ និងថវិកាមួយចំនួនសម្រាប់ចូលរួមអបអរសាទរខួបអន្តរជាតិនារី លើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣

-បានរៀបចំពិធីអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ ក្រោមមូលបទ "ស្ត្រីរួមគ្នារក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍក្នុងយុគសម័យឌីជីថល" នៅសាលបណ្ណាល័យព្រឹទ្ធសភា

-បានធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ជូនលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស (កាយរិទ្ធ) នៃវិទ្យាល័យបាភ្នំ ខេត្តព្រៃវែងចំនួន៥០នាក់

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភា ចំនួន៣៥នាក់

-បានផ្តល់សៀវភៅជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងមជ្ឈមណ្ឌលឯកសារកងយុទ្ធពលខេមរភូមិន្ទភូមិភាគទី៥ ខេត្តបាត់ដំបងចំនួន១៧ក្បាល

-បានផលិត និងផ្សព្វផ្សាយទស្សនាវដ្តីប្រចាំខែមីនា ឆ្នាំ២០២៣ ចំនួន៨០០ក្បាល

-បានរៀបចំផលិតខ្សែវីដេអូសមិទ្ធផលស្តីពី វឌ្ឍនភាពការងារក្រុមសមាជិកាព្រឹទ្ធសភា ឆ្នាំ២០២២

-បានចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា គោរពជូន ឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការ កងទ័ពជើងគោក ក្នុងឱកាសដែលព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សព្វព្រះរាជហឫទ័យ ត្រាស់បង្គាប់ដំឡើងឋានន្តរសក្តិជា "នាយឧត្តមសេនីយ៍"

-បានរៀបចំសារលិខិតថ្វាយព្រះពរ ជូនពរ និងអបអរសាទររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទូលថ្វាយ**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ, **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា និង ឥស្សរជនជាន់ខ្ពស់តាមក្រសួង ស្ថាប័ននានា ក្នុងឱកាសនៃការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ និងចម្រើនជន្មាយុចំនួន១៤លិខិត

-បានអញ្ជើញចូលរួមពិធីគោរពវិញ្ញាណក្ខន្ធ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនលោកស្រី **អី ធារីក្ស** ព្រមទាំងក្រុមគ្រួសារចំពោះមរណភាពរបស់លោក **តែ ប៊ុនលី** និវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានចាត់ចែង និងផ្សព្វផ្សាយញត្តិថ្កោលទោសរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ថ្កោលទោសទណ្ឌិត **សម រង្ស៊ី** ដែលបានប្រមាថព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

-បានទទួលពាក្យបណ្តឹងចំនួន០៣ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធ ចំនួន០២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៣ករណី កំពុងពិនិត្យសិក្សាចំនួន០៣ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០២ករណី និងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធ ចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបចំនួន០២ករណី។

**៤-មុខងារសហប្រតិបត្តិការអន្តរជាតិ**

-បានរៀបចំទីកន្លែង និងផ្តល់សេវាជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា៖

- ❖ ក្នុងពិធីទទួលសារតាំងពីឯកឧត្តម **Mohammed Ismaeil A.Dahlwy** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព ទើបតែងតាំងថ្មី នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ប្រចាំព្រះរាជាណាចក្រកម្ពុជា

❖ ក្នុងពិធីជំនួបសម្តែងការគួរសមជាមួយឯកឧត្តម **Dato' Seri Anwar bin Ibrahim** នាយករដ្ឋមន្ត្រី នៃប្រទេសម៉ាឡេស៊ី និងឯកឧត្តម **Victor Oh** សមាជិកព្រឹទ្ធសភាប្រទេសកាណាដា

-បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបពិភាក្សាការងារជូនសមាជិកព្រឹទ្ធសភា ជាមួយៈ

❖ ឯកឧត្តម **OLIVIER CADIC** សមាជិកព្រឹទ្ធសភាបារាំង ដើម្បីឈ្វេងយល់អំពីការអនុវត្តការងារនីតិកម្ម និងការងារការទូតរបស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

❖ លោក **GREG Moran** ភ្នាក់ងារស៊ុយអែត ដើម្បីកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍អន្តរជាតិ Sida ក្នុងគោលបំណង ដើម្បីឈ្វេងយល់អំពីលទ្ធផលនៃការផ្តល់សេវាគាំទ្រផ្នែកស្រាវជ្រាវ និងសារពើពន្ធ

❖ អ្នកវិនិយោគជនជាតិជប៉ុនលោក **EIjI Hatano** និងភ្ញៀវជាតិចំនួន១០០នាក់ អញ្ជើញមកសិក្សាឈ្វេងយល់អំពីការងារកសិកម្ម កសិឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍ ម៉ុង ឫទ្ធី សែនជ័យ

-បានរៀបចំ សម្របសម្រួលបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានា រួមមានៈ

❖ អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកិច្ចការសភា និងបណ្តាញស្ត្រី នៃសភាប្រើភាសាបារាំង (APF) នៅព្រះរាជាណាចក្រម៉ារ៉ុក

❖ អញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៤៦ (IPU-146) និងកិច្ចប្រជុំបណ្តាញសភា នៃក្រុមប្រទេសចលនាមិនចូលបក្សសម្ព័ន្ធ(NAM) នៅព្រះរាជាណាចក្របារ៉ែន

❖ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរទិវាបុណ្យជាតិ នៃប្រទេសគុយវ៉ែត ដែលរៀបចំឡើងដោយស្ថានទូតគុយវ៉ែត ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ

❖ អញ្ជើញចូលរួមជាកិត្តិយសអបអរសាទរពិធីចម្រើនព្រះជន្មព្រះចៅអធិរាជជប៉ុន ដែលរៀបចំឡើងដោយស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ

❖ អញ្ជើញដឹកនាំសម្របសម្រួលកិច្ចប្រជុំរវាងឯកឧត្តម **ហ៊ឺ បាវី** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ ជាមួយគណៈប្រតិភូ នៃសាធារណរដ្ឋកូរ៉េ ស្តីពី ការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការវិនិយោគ ដែលគ្រោងនឹងចុះអនុស្សរណៈនៃការយោគយល់គ្នា(MOU)

❖ អញ្ជើញចូលរួមពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានៈ

❖ អញ្ជើញចូលរួមកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក(ASGP)នៅព្រះរាជាណាចក្របារ៉ែន។ ក្នុងឱកាសនោះ ឯកឧត្តមអគ្គលេខាធិការបានៈ

- អញ្ជើញទស្សនា និងឈ្វេងយល់អំពីប្រព័ន្ធសភា នៃព្រះរាជាណាចក្របារ៉ែន
- ជួបពិភាក្សាការងារជាមួយអគ្គលេខាធិការសភានានា ដើម្បីពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ
- ផ្តល់បទពិសោធន៍ពាក់ព័ន្ធនឹងការផ្តល់សេវាសភា ការពង្រឹងសមត្ថភាពសភា ការលើកកម្ពស់ និងការអភិវឌ្ឍធនធានមនុស្ស

❖ ជួបពិភាក្សាការងារជាមួយអនុប្រធានស្ថានទូតជប៉ុន និងលោក **Wu Guoguan** ទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្ម នៃស្ថានទូតសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា

-បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតសិង្ហបុរី, ស្ថានទូតចិន, ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេ, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ស្ថានទូតវៀតណាម,ទីស្តីការគណៈរដ្ឋមន្ត្រី, អង្គការមូលនិធិអាស៊ី, មូលនិធិសន្តិភាពដើម្បីអភិវឌ្ឍ, ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា(CDC), សាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃទីក្រុងហាណូយ(USTH), សាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃទីក្រុងហាណូយ(RMIT), សាកលវិទ្យាល័យលីមកុកវីង, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, មជ្ឈមណ្ឌលសភាអាស៊ី(PCAsia), បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា(CADT), វិទ្យាស្ថានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, វិទ្យាស្ថានProseth, វិទ្យាស្ថានSunrise, វិទ្យាស្ថានSalaCyber, វិទ្យាស្ថានជាតិស្ថិតិ(NIS), វិទ្យាស្ថានជាតិសង្គមកិច្ច, សាលារៀនខេម-អាស៊ាន, សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, ក្រុមហ៊ុន KOHA និងក្រសួង ស្ថាប័ន បណ្ណាល័យនានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-បានទទួលជំនួយរថយន្តពីសាធារណរដ្ឋប្រជាមានិតចិន តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន០៥គ្រឿង និងពីសាធារណរដ្ឋកូរ៉េ តាមរយៈអង្គការបក្សីខៀវចំនួន០១គ្រឿង

-បានធ្វើបទបង្ហាញស្តីពី ការចែករំលែកបទពិសោធន៍កិច្ចការសភារបស់សាធារណរដ្ឋបារាំងជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានចូលរួមប្រជុំកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានប្រជុំគណៈកម្មការ (PFM) ផ្ទៃក្នុង និងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា និងប្រចាំត្រីមាសទី១ ព្រមទាំងលើកទិសដៅការងារបន្ត ឆ្នាំ២០២៣

-បានប្រជុំបូកសរុបលទ្ធផលការងាររបស់គណៈកម្មការសមាគមមូលដ្ឋានអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៃសមាគមសង្គហៈ ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣

-បានប្រជុំគណៈកម្មការដំឡើងថ្នាក់បៀវត្ស ឆ្នាំ២០២៣ និងគណៈកម្មការផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានប្រជុំត្រួតពិនិត្យ និងពិភាក្សាការងារសំខាន់ៗ និងលើកទិសដៅការងារសម្រាប់អនុវត្តបន្តរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល ក្នុងបរិបទសេដ្ឋកិច្ចសកលស្ថិតក្នុងស្ថានភាពមិននឹងន

-បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មីៗ

**៥.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖**

-បានបើកប្រាក់បៀវត្សប្រចាំខែមីនា ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា បានទាន់ពេលវេលា

-បានតាមដានគោលការណ៍ និងព័ត៌មានទាក់ទងនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

-បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៤៦៥សំណើ

-បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន៨៣សំណើ

-បានថតចម្លងឯកសារចំនួន៦,៩០៣ច្បាប់ អស់ក្រដាសសរុបចំនួន៤៨,៧៥៨សន្លឹក

-បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិ-

ការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុងចំនួន៣៦៨លើក ស្មើនឹង៤២៤នាក់។

-បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២៦លើក ស្មើនឹង១,៥២០នាក់

-បានទទួលលិខិតចូលចំនួន៤៩៨ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣៨៨ច្បាប់

-បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៦៧ច្បាប់ ស្មើនឹង២២៨នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០៩ច្បាប់ ស្មើនឹង០៩នាក់

-បានចុះសួរសុខទុក្ខមន្ត្រីរាជការមានជំងឺ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៦នាក់

-បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២១០លីត្រ ជូនអង្គភាពចំណុះអគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា

-បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានាចំនួន១២លើក ព្រមទាំងបានដាំដើមឫស្សី និងដើមតយចំនួន៦០គុម្ព

-បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា ព្រមទាំងបានបាញ់សម្អាតផ្លូវ និងក្រោមអគារក្រហម និងធុងសំរាមធំ

-បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការថែរក្សាអនាម័យបរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការថែរសន្តិសុខ និងសណ្ដាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

-បានទទួលលិខិតសុំអនុញ្ញាតច្បាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងកត់ត្រាចូលក្នុងសៀវភៅការងារចំនួន៧០ច្បាប់

-បានធ្វើសេចក្ដីសម្រេច និងលិខិតបង្គាប់ការចំនួន០៧ច្បាប់

-បានធ្វើប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភាចំនួន៧២ប័ណ្ណ

-បានបើកវគ្គបណ្ដុះបណ្ដាលក្នុងប្រទេសចំនួន០២វគ្គ មានសិក្ខាកាមចូលរួមចំនួន២០នាក់ និងក្រៅប្រទេសចំនួន០៣វគ្គ មានសិក្ខាកាមចូលរួមចំនួន០៦នាក់ ព្រមទាំងសិក្ខាសាលា បាឋកថាក្នុងប្រទេសចំនួន០២លើក មានសិក្ខាកាមចូលរួមចំនួន៦០នាក់

-បានធ្វើរបាយការណ៍វាយតម្លៃការធ្វើបទបង្ហាញរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

នៃវគ្គបណ្តុះបណ្តាលនានាចំនួន០២លើក និងរបាយការណ៍ស្ទង់មតិអំពី "ការពេញចិត្ត និងការបំពេញការងារនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា"

-បានជួសជុល កែលម្អអគារក្រហម និងអគារគណៈកម្មការទី១០, លាបថ្នាំអគារមូលនិធិ និងបាំងបន្ទប់កញ្ចក់អាលុយមីញ៉ូមទូម៉ាស៊ីនRack នៅអគារជប៉ុន និងអគារA.B.C

-បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី, ត្រួតពិនិត្យដំណើរយន្តសត្វកណ្តៀរ, រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម, ប្រមូលសម្ភារខូច, បិទលេខកូដសម្ភារសារពើភ័ណ្ឌ, ប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណព្រឹទ្ធសភាចំនួន២០៧គ្រឿង/លើក

-បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើងក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន៣៨លើក

-បានធ្វើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចន្លោះសម័យប្រជុំលើកទី៩ និងលើកទី១០ នីតិកាលទី៤

-បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមីនា ឆ្នាំ២០២៣ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

-បានធ្វើបទបង្ហាញស្តីពី លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ២០២៣ និងលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំត្រីមាសទី១ និងទិសដៅការងារត្រីមាសទី២ ឆ្នាំ២០២៣

-បានធ្វើសម្រង់ស្ថិតិ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែមីនា ឆ្នាំ២០២៣ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា

-បានធ្វើរបាយការណ៍ស្តីពី ការពិនិត្យ និងតាមដានការអនុវត្តផែនការប្រតិបត្តិរបស់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានទាំង៥ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣

-បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន០៦លើក។

**៥.២-ការងារសៅវ៉ាច្បាប់៖**

-បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច ប្រកាស សារាចរណែនាំ របាយ-ការណ៍ សេចក្ដីជូនដំណឹង និងលិខិតផ្សេងៗចំនួន២២២ច្បាប់

-បានផ្ញើកំណត់បង្ហាញរបាយការណ៍សវនកម្មចំនួន០២ច្បាប់

-បានបោះពុម្ពកំណត់ហេតុសង្ខេប និងពិស្ដារព្រឹទ្ធសភា ឆ្នាំ២០២២

-បានចងក្រងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមរបប ២ឆ្នាំ

-បានប្រមូលចងក្រង និងសង្ខេបព័ត៌មានជាតិ និងអន្តរជាតិចំនួន១,៤៥៣អត្ថបទ

-បន្តចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និងនីតិកាលនីមួយៗ។

**៥.៣-ការងារស្រាវជ្រាវ៖**

-បានសិក្សា ស្រាវជ្រាវ ប្រមូលព័ត៌មាន និងផលិតអត្ថបទស្ដីពី បម្រែបម្រួលទីផ្សារប្រេងសាំងនាពេលបច្ចុប្បន្នក្នុងព្រះរាជាណាចក្រកម្ពុជា

-បានតាមដាន និងសិក្សាការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ

-បានសិក្សាស្រាវជ្រាវ និងធ្វើសំយោគឯកសារព័ត៌មាន និងសង្ខេបខ្លឹមសារពាក់ព័ន្ធនឹងវិស័យនានាចំនួន៨២ច្បាប់

-បានតាមដាន និងចងក្រងឯកសារវាយតម្លៃពាក់កណ្ដាលអាណត្តិ នៃការអនុវត្តគោលនយោបាយឧស្សាហកម្ម (ឆ្នាំ២០១៥-២០២៥)

-បានផលិតទិន្នន័យតាមវិស័យរបស់គណៈកម្មការជំនាញទាំង១០ចំនួន៦៣ច្បាប់

-បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន១១០អត្ថបទ

-បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែមីនា ឆ្នាំ២០២៣ ចំនួន០២ច្បាប់។

**៥.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

-បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលកុំព្យូទ័រ និងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន៧២គ្រឿង/លើក

-បានបន្តបំពាក់ឧបករណ៍អេឡិចត្រូនិចមានដូចជា កុំព្យូទ័រយួរដៃ កុំព្យូទ័រលើតុ Ipad និងPrinter ជូនសមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១២គ្រឿង

-បានរៀបចំកម្មវិធីទូរស័ព្ទ (Mobile Application) សម្រាប់គាំទ្រទៅលើការផ្សព្វផ្សាយពីដំណើរការ

និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងសាធារណជន

-បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅជំនាញផ្សេងៗចំនួន១៧៧ក្បាល ព្រមទាំងអ៊ុតក្រប សៀវភៅចំនួន១០០ក្បាល

-បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ និង ឯកសារទទួលបានថ្មីៗ តាមបណ្ដាញ Facebook និងតាម E-book ដែលមានអ្នកចូលអាន និងចុចLikeចំនួន ៨,៨៧០នាក់

-បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្ដីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងារព្រឹទ្ធសភា ចំនួន១៦លើក

-បានថត និងផ្សព្វផ្សាយព័ត៌មានស្ដីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងារព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube, Facebook និងTiktokចំនួន២៤៣លើក

-បានបញ្ចូលព័ត៌មានស្ដីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និង ថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងារព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន២៨៧ប្រធានបទ

-បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Channel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន២,២៧៦ប្រធានបទ

-បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៣៦លើក និងទស្សន-ព័ត៌មានប្រចាំថ្ងៃចំនួន១៦លើក

-បានតុបតែងលម្អ តាំងពិព័រណ៍រូបភាពនៅមុខអគារក្រហម និងខ្លោងទ្វារធំព្រឹទ្ធសភាចំនួន១២លើក

-បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្ដាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិត ខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿនល្អ និងរលូនៗ

**៥.៥-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

-បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៤០លើក

-បានកសាងជំនួយស្មារតីជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភាចំនួន០៣ច្បាប់

-បានរៀបចំលិខិតអបអរសាទររបស់**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា** អនុប្រធានទី១ព្រឹទ្ធសភា ជូនឯកឧត្តម Wang Huning ក្នុងឱកាសដែលឯកឧត្តមត្រូវបានបោះឆ្នោតជ្រើសរើសជាប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន

-បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែមីនា ឆ្នាំ២០២៣ ចំនួន០១ច្បាប់។

**៥.៦-ការងារអគ្គាធិការដ្ឋាន៖**

-បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា ឆ្នាំ២០២៣ ចំនួន១៩លើក

-បានប្រជុំពិភាក្សាការងារជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងធ្វើរបាយការណ៍ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃចំនួន៤៤លើក ប្រចាំសប្តាហ៍ចំនួន០៤លើក និងប្រចាំខែមីនា ឆ្នាំ២០២៣

-បានចុះត្រួតពិនិត្យស្រង់វត្តមានចំនួន០១លើក ជាក់ស្តែងតាមនាយកដ្ឋាន ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងផ្ទៃក្នុងនៃអគ្គាធិការដ្ឋានរៀងរាល់ថ្ងៃ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ

-បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា

-បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែមីនា ឆ្នាំ២០២៣។

II-ទិសដៅការងារខែមេសា ឆ្នាំ២០២៣

-ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ ជំងឺកូវីដ-១៩ ជំងឺរាតត្បាតថ្មី និងគ្រោះធម្មជាតិ

-បន្តប្រឈមការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក

-ធានាប្រសិទ្ធភាព ប្រសិទ្ធផល សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា។

**១- មុខងារនីតិកម្ម**

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

**២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋាន ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ចូលរួមពិធីសាសនា និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

-ត្រៀមរៀបចំជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ នៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ (ថ្ងៃទី០៧-២០ ខែមេសា ឆ្នាំ២០២៣)

-ត្រៀមរៀបចំជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលឃុំ និងមេភូមិ នៅខេត្តបន្ទាយមានជ័យ (ខែមេសា ឆ្នាំ២០២៣)

-ត្រៀមរៀបចំជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ តាមបណ្តាខេត្ត ក្រុងនានា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំក្នុងពិធីជំនួបជាមួយឥស្សរជនជាន់ខ្ពស់បរទេស និងអគ្គរដ្ឋទូតនានា នៃប្រទេសជាមិត្ត

-ត្រៀមទទួលដំណើរទស្សនកិច្ច៖

- គណៈប្រតិភូអគ្គលេខាធិការសភាថៃ
- គណៈកម្មការគោលនយោបាយសង្គមកិច្ចរបស់ព្រឹទ្ធសភា នៃសាធារណរដ្ឋឆែក

-ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញ៖

- ចូលរួមកិច្ចប្រជុំគណៈកម្មការនយោបាយ និងក្រុមការងារទទួលបន្ទុកសើរើលក្ខន្តិកៈនៃសភាប្រើភាសាបារាំង(APF) នៅសាធារណរដ្ឋបារាំង
- ចូលរួមប្រជុំគណៈកម្មាធិការមហាសន្និបាតនៃសភាប្រើភាសាបារាំង(APF)
- ចូលរួមកម្មសិក្សា នៅព្រឹទ្ធសភាកាណាដា (ថ្ងៃទី២៤-២៨ ខែមេសា ឆ្នាំ២០២៣)

-ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម (ថ្ងៃទី០៣-០៦ ខែមេសា ឆ្នាំ២០២៣)

-ផ្ដល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស មជ្ឈមណ្ឌលសភាអាស៊ី(PCAsia) និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន

-ជំរុញកម្មវិធីបណ្ដុះបណ្ដាលមន្ត្រីក្នុង និងក្រៅប្រទេស តាមកម្មវិធីសហប្រតិបត្តិការជាមួយភាគីជាមិត្ត និងដៃគូអភិវឌ្ឍផ្សេងៗទៀត។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

-ត្រៀមរៀបចំគម្រោងថវិការបស់ព្រឹទ្ធសភាឆ្នាំ២០២៤

-ត្រៀមប្រជុំគណៈកម្មការពិសេស សិក្សា និងកែសម្រួលគោលការណ៍ហិរញ្ញវត្ថុសំខាន់ៗរបស់ព្រឹទ្ធសភា

-ត្រៀមប្រជុំគណៈកម្មការកសាងផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល (ឆ្នាំ២០២៤-២០២៦)

-ត្រៀមបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងភ្នាក់ងារសន្តិសុខនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់ខែមេសា និងប្រាក់ឧបត្ថម្ភសម្រាប់ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ និងប្រាក់ឧបត្ថម្ភផ្សេងៗ ឆ្នាំ២០២៣ ឱ្យបានទាន់ពេលវេលា

-បន្តវិចារណកម្មថវិកាៈ សន្សំសំចៃ និងអាទិភាពចំពោះតែការងារចាំបាច់បន្ទាន់ និងប្រញាប់បំផុតៈ

- ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក
- ចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ

-ត្រៀមរៀបចំពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

-ត្រៀមរៀបចំឯកសារគោលស្តីពី តួនាទី ភារកិច្ចរបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារពិពណ៌នាការងារ និងបញ្ជាក់ពីសមត្ថភាពធ្វើការងាររបស់មន្ត្រីរាជការ

-ត្រៀមរៀបចំការងារកែសម្រួលឋានន្តរសក្តិ និងការតែងតាំងក្នុងមុខតំណែង

-ត្រៀមប្រឡងប្តូរក្របខ័ណ្ឌ សម្រាប់មន្ត្រីរាជការបានរៀនបញ្ចប់សញ្ញាបត្រថ្មីដែលខ្ពស់ជាងក្របខ័ណ្ឌបច្ចុប្បន្ន

-ត្រៀមរៀបចំគោលការណ៍ គោលនយោបាយថ្មីៗ ស្របតាមដំណើរការងារ និងស្ថានភាពជាក់ស្តែង ចំនួន០៣គឺៈ

១-គោលការណ៍ស្តីពី ការផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការមានស្នាដៃឆ្នើម

២-គោលការណ៍ស្តីពី ការវាយតម្លៃការបំពេញការងាររបស់មន្ត្រីរាជការ

៣-គោលនយោបាយស្តីពី ការគ្រប់គ្រងធនធានមនុស្ស

-ត្រៀមធ្វើជំរឿនសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស តម្រូវការ និងការប្រឈម

-ធ្វើបច្ចុប្បន្នភាពផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សរយៈពេល១០ឆ្នាំ (២០២២-២០៣០) របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ត្រៀមបើកវគ្គបណ្តុះបណ្តាលលើមុខជំនាញដែលជាតម្រូវការចាំបាច់របស់ស្ថាប័ន

-ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពីៈ វគ្គសេដ្ឋកិច្ច ឌីជីថល, វគ្គវិភាគសារពើភ័ណ្ឌ ទ្រព្យសម្បត្តិរដ្ឋ, វគ្គFiscal Analysis Capacity Training to Assess Health and Emergency Responses, វគ្គAdvanced English Language and Communication Skill នៅមជ្ឈមណ្ឌលICON និងវគ្គSpecialized Training Programme on Select WTO Issues Agriculture Services TRIPS and RTAS នៅប្រទេសឥណ្ឌា

-បន្តតាមដានជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានទូតចិន ស្ថានទូតវៀតណាម ទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្មចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា លើគម្រោងស្នើកសាងអគារថ្មី១ខ្នង និងការស្វែងរកជំនួយពីរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មីខាងមុខ

-បន្តសិក្សាគម្រោង និងប្លង់សាងសង់សាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថ្មី ប្លង់សាងសង់របងថ្មីខាងមុខព្រឹទ្ធសភា និងជួសជុលសាលបដិសណ្ឋារកិច្ច

-ត្រៀមរៀបចំផែនការការងារសម្រាប់ការត្រៀមទទួលនីតិកាលទី៥ របស់ព្រឹទ្ធសភា និងការត្រៀមជាបណ្តើរៗ ការរៀបចំជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារការិយាល័យធ្វើការ រួមទាំងការបំពាក់សម្ភារៈ

-បន្តការងារជួសជុលថែទាំអគារ ជួសជុលអគារក្រហម និងជួសជុលផ្លាស់ប្តូរគ្រឿងបរិក្ខារផ្សេងៗនៅតាមអគារ

-បន្តកសាងរបង និងជួសជុល លាបថ្នាំរបងជុំវិញព្រឹទ្ធសភា

-បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

-លើកកម្ពស់សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង សម្ភារៈ និងបច្ចេកវិទ្យាព័ត៌មាន ឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិច-

ត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ព្រមទាំងការចូលរួមវគ្គផ្សេងៗ រៀបចំដោយសភានៃប្រទេសជាមិត្ត

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-ត្រៀមរៀបចំផលិតខ្សែវីដេអូព័ត៌មានរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

III-**សេចក្តីសន្និដ្ឋាន**

*ក្នុងខែមីនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារផ្តល់សេវាលើមុខងារទាំង៥ សម្រេចបានលទ្ធផលល្អប្រសើរ។*

*ស្នាដៃថ្មីមួយរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលបានរួមចំណែកនៅក្នុងគណៈកម្មការពិសេស ដើម្បីធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍ និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា បានពិនិត្យ និងអនុម័តជាស្ថាពរ សម្រាប់ដំណើរការរបស់ស្ថាប័ន ស្របតាមបរិបទថ្មីការកែទម្រង់របស់ស្ថាប័ន និងប្រទេសជាតិ។*

*ក្នុងខែនេះផងដែរ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏សម្រេចបានលទ្ធផលជាច្រើនក្នុងការផ្តល់សេវាលើមុខងារតំណាង ដែលជារដូវកាលសមាជិកព្រឹទ្ធសភា ចុះជាប់ជាមួយមូលដ្ឋានក្នុងដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតសកល នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣។*

*ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ នៅតែបន្តសកម្មភាព និងកិច្ចសហប្រតិបត្តិការឥតឈប់ឈរ ដោយបានចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៤៦ (IPU-146) និងកិច្ចប្រជុំសមាគមអគ្គ-លេខាធិការសភាពិភពលោក(ASGP)។*

*មន្ត្រីរាជការទាំងអស់ ត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការនានា ដែលរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលបានដាក់ចេញ ជាពិសេសវិធានការ "៣ការពារ ៣កុំ" និងការចាក់វ៉ាក់សាំងដូសជំរុញឱ្យបានគ្រប់ៗគ្នាកុំបីខាន ដើម្បីការពារមិនឱ្យជំងឺកូវីដ-១៩ ឆ្លងរាលដាលជាថ្មីទៀតបាន។*

*ថ្ងៃចន្ទ ១៣កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦*

*រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣*

**អគ្គលេខាធិការស្តីទី**

**ឡោក_ឆាយ**